01066639

E329/8

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 18 / 02 / 2015
ម៉ោង (Time/Heure) : 15:25
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសង

**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **Claudia FENZ** |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# សេចក្តីសម្រេចលើកទីពីរ នៅលើសម្បទារបស់ជនជាប់ចោទ ខៀវ សំផន ក្នុងការចូលរួមសវនាការ

| | |
|---|---|
| **សហព្រះរាជអាជ្ញា** | **ជនជាប់ចោទ** |
| ជា លាង | នួន ជា |
| Nicholas KOUMJIAN | ខៀវ សំផន |
| **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី** | **មេធាវីជនជាប់ចោទ** |
| ពេជ អង្គ | សុន អរុណ |
| Marie GIRAUD | Victor KOPPE |
| | គង់ សំអុន |
| | Arthur VERCKEN |
| | Anta GUISSÉ |

## ១. ប្រវត្តិនីតិវិធី

១. អនុលោមតាមវិធាន ៣២ នៃវិធានផ្ទៃក្នុង តាមឆន្ទានុសិទ្ធិរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានចាត់តាំងអ្នកជំនាញពីររូបគឺ វេជ្ជបណ្ឌិត CHAN Kin Ming និងវេជ្ជបណ្ឌិត ហួត លីវណា ("អ្នកជំនាញ") ដើម្បីពិនិត្យវាយតម្លៃជនជាប់ចោទ និងធ្វើរបាយការណ៍ស្តីពីសម្បទារបស់ពួកគេក្នុងការចូលរួមសវនាការ[1]។ បន្ទាប់ពីបានពិនិត្យវាយតម្លៃជនជាប់ចោទទៅតាមដីកាបង្គាប់របស់អង្គជំនុំជម្រះរួចហើយ អ្នកជំនាញបានដាក់របាយការណ៍របស់ខ្លួននៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥[2]។ នៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ បន្ទាប់ពីមានសំណើសុំពីអង្គជំនុំជម្រះ អ្នកជំនាញបានផ្តល់យោបល់បន្ថែមទៀតស្តីពីរយៈពេលសវនាការសម្រាប់ថ្ងៃនីមួយៗ ដែលសមស្របសម្រាប់ជនជាប់ចោទ និងបានលើកឡើងនូវផលប៉ះពាល់នៃបញ្ហាសុខភាពជាក់លាក់នាពេលថ្មីៗ ដែល ខៀវ សំផន ជួបប្រទះក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីសវនាការ[3]។ ចៅក្រម និងភាគីមានឱកាស

[1] ដីកាចាត់តាំងអ្នកជំនាញដើម្បីវាយតម្លៃលើសម្បទារបស់ជនជាប់ចោទ ក្នុងការចូលរួមសវនាការ ("ដីកា") ឯកសារ E329 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥។

[2] របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ៖ ខៀវ សំផន ("របាយការណ៍ស្តីពី ខៀវ សំផន") ឯកសារ E329/5 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥។ របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ៖ នួន ជា ឯកសារ E329/4 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥។

[3] សារអេឡិចត្រូនិកពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ផ្ញើជូនអង្គជំនុំជម្រះសាលាដំបូង ក្នុងការឆ្លើយតបទៅនឹងឯកសារ E329/6 ("សារអេឡិចត្រូនិកលើកទី១ របស់អ្នកជំនាញ") ឯកសារ E329/6/1 ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។ សារអេឡិចត្រូនិកលើកទី២ ពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ផ្ញើជូនអង្គជំនុំជម្រះសាលាដំបូងក្នុងការឆ្លើយតបទៅនឹងឯកសារ E329/6 ("សារអេឡិចត្រូនិកលើកទី២ របស់អ្នកជំនាញ") ឯកសារ E329/6/2 ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។ អង្គជំនុំជម្រះបានទទួលសំណើមួយពីមេធាវីការពារក្តី ខៀវ សំផន ដែលបានស្នើសុំឱ្យចាត់ថ្នាក់ឡើងវិញនូវសុំសារអេឡិចត្រូនិកលើកទី១ របស់អ្នកជំនាញ ពីសម្ងាត់ ទៅជាសម្ងាត់បំផុត និងសុំឱ្យសារអេឡិចត្រូនិកលើកទី២ របស់អ្នកជំនាញ ស្ថិតនៅក្នុងការចាត់ថ្នាក់ជាសម្ងាត់បំផុតដដែល។ មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងថា សវនាការជាសាធារណៈស្តីពីសុខភាពរបស់ ខៀវ សំផន ផ្តល់នូវព័ត៌មានលំអិត និងពេញលេញស្តីពីសុខភាពរបស់ ខៀវ សំផន។ ប្រតិចារិកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ៥៩ ដល់ ៦០ (ភាសាអង់គ្លេស)។ ដោយពិចារណាថា អ្នកជំនាញបានពិភាក្សាពីព័ត៌មានដែលមាននៅក្នុងសារអេឡិចត្រូនិកទាំងពីរជាសាធារណៈ ក្នុងអំឡុងពេលស្តាប់សវនាការស្តីពីសម្បទារបស់ជនជាប់ចោទនៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា ការចាត់ថ្នាក់សារអេឡិចត្រូនិកលើកទី១ និងសារអេឡិចត្រូនិកលើកទី២ របស់អ្នកជំនាញ ជាសម្ងាត់បំផុត មិនបានបម្រើផលប្រយោជន៍សាធារណៈទេ។ ហេតុដូចនេះ អង្គជំនុំជម្រះនឹងចាត់ថ្នាក់ជាថ្មីចំពោះសារអេឡិចត្រូនិកទាំងពីរលើករបស់អ្នកជំនាញជាសាធារណៈ។

ក្នុងការសួរដេញដោលអ្នកជំនាញ ទៅលើរបាយការណ៍ និងមតិយោបល់របស់ពួកគេនៅក្នុងសវនាការជាសាធារណៈនៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥។

២. នៅក្នុងសវនាការថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ អ្នកជំនាញបានបំភ្លឺពីសេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់ពួកគេ។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំឱ្យអ្នកជំនាញបំភ្លឺពីសេចក្តីសន្និដ្ឋានរបស់ពួកគេនៅក្នុងសារអេឡិចត្រូនិកលើកទី១ ដែលថា សវនាការរយៈពេលបួនថ្ងៃក្នុងមួយសប្តាហ៍ជាការសមស្របសម្រាប់ជនជាប់ចោទ។ អ្នកជំនាញក៏បានពិភាក្សាផងដែរ ពីលទ្ធផលនៃការពិនិត្យទៅលើ ខៀវ សំផន ដោយអង្គភាពវេជ្ជសាស្ត្រនៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ និងថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ បន្ទាប់ពីអង្គជំនុំជម្រះបានផ្អាកសវនាការមុនកាលកំណត់ ដោយមូលហេតុ ខៀវ សំផន មានបញ្ហាសុខភាព ។ សហព្រះរាជអាជ្ញាអន្តរជាតិ មេធាវីការពារក្តី ខៀវ សំផន មេធាវីការពារក្តី នួន ជា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏បានសួរដេញដោលទៅលើអ្នកជំនាញនាពេលសវនាការនោះដែរ។

៣. អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសន្និដ្ឋានថា ខៀវ សំផន មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ[4]។ ដើម្បីសម្រេចថាតើ គាត់នៅតែមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការឬយ៉ាងណានោះ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យអ្នកជំនាញរាយការណ៍ពីព័ត៌មានដែលអាចជួយឱ្យអង្គជំនុំជម្រះសម្រេចពីសម្បទារបស់ជនជាប់ចោទ អនុលោមទៅតាមលក្ខណៈវិនិច្ឆ័យដែលមានរៀបរាប់នៅក្នុងសាលដីកាលើបណ្តឹងសាទុក្ខក្នុង *រឿងក្តី Strugar*[5]។

## ២. ការពិនិត្យ វាយតម្លៃដោយអ្នកជំនាញ

៤. ចាប់ពីពេលដែលអង្គជំនុំជម្រះចេញសេចក្តីសម្រេចលើ ខៀវ សំផន លើកទី១ ខៀវ សំផន បានចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យចំនួនបីដង៖ នៅថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៤ ដោយសារបញ្ហារលាកសួត នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៤ ដោយសាររោគសញ្ញារលាកទងសួត និងនៅ

---

[4] សេចក្តីសម្រេចលើសម្បទារបស់ជនជាប់ចោទ ខៀវ សំផន ក្នុងការចូលរួមសវនាការ ("សេចក្តីសម្រេចលើ ខៀវ សំផន លើកទី១") ឯកសារ E301/12 ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤។

[5] ដីកា កថាខណ្ឌ ៧ ដោយដកស្រង់ចេញពី *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Strugar* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY សំណុំរឿងលេខ IT-01-42-A សាលដីកា ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨ ("*រឿងក្តី Strugar*") កថាខណ្ឌ ៥៥ (ភាសាអង់គ្លេស)។

ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៥ ដោយសារបញ្ហានានាទាក់ទងនឹងរោគរលាកទងសួត សម្ពាធឈាមឡើងខ្លាំង និងបញ្ហាបេះដូង[6]។ អ្នកជំនាញបានពិនិត្យវាយតម្លៃ ខៀវ សំផន នៅថ្ងៃទី ១៩ ទី ២០ និង ទី ២២ ខែ មករា ឆ្នាំ ២០១៥ ពិនិត្យទៅលើរបាយការណ៍វេជ្ជសាស្ត្រប្រចាំសប្តាហ៍របស់គ្រូពេទ្យប្រចាំការនៅមន្ទីរឃុំឃាំង អ.វ.ត.ក និង មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅទីក្រុងភ្នំពេញ និងបានសម្ភាសគ្រូពេទ្យប្រចាំការដែលព្យាបាល ខៀវ សំផន នៅមន្ទីរឃុំឃាំង[7]។ អ្នកជំនាញបានសន្និដ្ឋានថា ខៀវ សំផន ហាក់មានសុខភាពល្អ ទោះបីគាត់មានបញ្ហាសុខភាពមួយចំនួនក៏ដោយ ហើយថា ពុំឃើញមានបញ្ហាផ្នែករូបកាយណាមួយដែលនឹងប៉ះពាល់ដល់លទ្ធភាពរបស់គាត់ក្នុងការចូលរួមសវនាការទេ[8]។ អ្នកជំនាញក៏បានសន្និដ្ឋានផងដែរថា គាត់បានជាសះស្បើយទាំងស្រុងពីជំងឺរលាកផ្លូវដង្ហើមដែលគាត់ឈឺតាំងពីថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៤ និងជំងឺរលាកទងសួតដែលគាត់បានឈឺនៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៤[9]។ អ្នកជំនាញបានកត់សម្គាល់ថា ខៀវ សំផន អាចក្រោកពីគ្រែមកអង្គុយបានលឿនជាងមុន ធ្វើតាមការណែនាំបានល្អ និងហាត់ប្រាណដើរមួយៗដោយប្រើដែកច្រត់ អានឯកសារច្រើន និងរៀបចំឯកសាររបស់គាត់នៅក្នុងកុំព្យូទ័រ[10]។

៥. អ្នកជំនាញបានសន្និដ្ឋានថា មិនចាំបាច់មានការកែប្រែស្ថានភាពរូបវន្តនៅក្នុងបន្ទប់សវនាការ ដើម្បីធានាឲ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពបំផុតពី ខៀវ សំផន នៅពេលសវនាការនោះទេ[11]។ អ្នកជំនាញក៏មានយោបល់ផងដែរថា នាពេលនេះ ខៀវ សំផន មិនមានបញ្ហាផ្លូវចិត្ត ឬបញ្ហាស្មារតី ដែលអាចធ្វើឲ្យប៉ះពាល់ដល់សមត្ថភាពរបស់គាត់ក្នុងការចូលរួមក្នុងសវនាការ ដូចដែលបានកំណត់នៅក្នុង*រឿងក្តី Strugar* នោះទេ[12]។ ផ្ទុយទៅវិញ អ្នកជំនាញយល់ថា ការចងចាំក្នុងរយៈពេលខ្លី ការផ្តង់អារម្មណ៍ និងការយកចិត្តទុកដាក់របស់ ខៀវ សំផន មានភាពល្អប្រសើរបំផុត

---

[6] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ៧។ ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ២៤ (ភាសាអង់គ្លេស)។

[7] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ៣។ ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ៩, ២៤ (ភាសាអង់គ្លេស)។

[8] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ៣៩។ ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១៣ ដល់ ១៥ (ភាសាអង់គ្លេស)។

[9] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ៨។ ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១៤ ដល់ ១៥ (ភាសាអង់គ្លេស)។

[10] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ៩។ ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១៤ (ភាសាអង់គ្លេស)។

[11] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ៤២។

[12] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ៤៤។ ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១៣ (ភាសាអង់គ្លេស)។

ស្របទៅតាមវ័យរបស់គាត់[13]។ អ្នកជំនាញបានសន្និដ្ឋានជាពិសេសថា ខៀវ សំផន មានសមត្ថភាពចាំបាច់នានាដែលមានរៀបរាប់នៅក្នុង *រឿងក្ដី Strugar*[14]។

៦. ដោយសារថា ការចងចាំ និងមុខងារផ្នែកបញ្ញាស្មារតីរបស់ ខៀវ សំផន អាចនឹងធ្លាក់ចុះខ្សោយជាបណ្ដើរៗទៅតាមវ័យរបស់គាត់ អ្នកជំនាញផ្ដល់អនុសាសន៍ឱ្យមានការពិនិត្យឡើងវិញជាទៀងទាត់ទៅលើមុខងារផ្នែកបញ្ញាស្មារតីរបស់គាត់ ជាពិសេស ប្រសិនបើមានការកត់សម្គាល់ឃើញថា ការចងចាំ ឬបញ្ញាស្មារតីរបស់គាត់មានការធ្លាក់ចុះគួរឱ្យកត់សម្គាល់[15]។ អ្នកជំនាញមិនមានភស្តុតាងបង្ហាញថា ខៀវ សំផន មានជំងឺ Alzheimer ឬទម្រង់ផ្សេងទៀតនៃជំងឺវង្វេងវង្វាន់ស្មារតី (dementia) ដែលអាចជាប់ទាក់ទងទៅនឹងការចុះខ្សោយយ៉ាងលឿននៃមុខងារផ្នែកបញ្ញាស្មារតីនោះទេ[16]។ នៅក្នុងសវនាការថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ អ្នកជំនាញបានផ្ដល់អនុសាសន៍ថា ដោយសារតែជនជាប់ចោទមានវ័យចំណាស់ ជនជាប់ចោទទាំងពីរនាក់គួរតែទទួលបានការពិនិត្យវាយតម្លៃជាទៀងទាត់ពីស្ថានភាពផ្លូវចិត្តរបស់គាត់[17]។ អ្នកជំនាញបានផ្ដល់អនុសាសន៍ថា ការវាយតម្លៃ និងការរាយការណ៍ស្ដីពីសុខភាពផ្លូវចិត្តគួរតែត្រូវបានធ្វើឡើងដោយអ្នកឯកទេសម្នាក់ជារៀង-រាល់ខែ ឬបីខែម្ដង[18]។ អ្នកជំនាញក៏បានផ្ដល់អនុសាសន៍ថា ដោយសារធ្លាប់មានជំងឺដាច់សសៃឈាមក្នុងខួរក្បាលរយៈពេលជាច្រើនឆ្នាំមកហើយ សម្ពាធឈាមរបស់ ខៀវ សំផន គួរតែត្រូវបានពិនិត្យតាមដានឱ្យបានជិតដល់ ប៉ុន្តែសម្ពាធឈាមនេះមិនគួរប៉ះពាល់លើលទ្ធភាពរបស់គាត់ក្នុងការចូលរួមសវនាការនោះទេ[19]។

---

[13] របាយការណ៍ស្ដីពី ខៀវ សំផន កថាខណ្ឌ ២៨។ ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១៣ (ភាសាអង់គ្លេស)។

[14] របាយការណ៍ស្ដីពី ខៀវ សំផន កថាខណ្ឌ ៣០ ដល់ ៣៧។ ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១៣ (ភាសាអង់គ្លេស)។

[15] របាយការណ៍ស្ដីពី ខៀវ សំផន កថាខណ្ឌ ៤៥។ ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ៤៣ ដល់ ៤៨ (ភាសាអង់គ្លេស)។

[16] របាយការណ៍ស្ដីពី ខៀវ សំផន កថាខណ្ឌ ៤៥។

[17] ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ៤៣ ដល់ ៤៨ (ភាសាអង់គ្លេស)។

[18] ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ២១ ដល់ ២២ (ភាសាអង់គ្លេស)។

[19] របាយការណ៍ស្ដីពី ខៀវ សំផន កថាខណ្ឌ ១៨។ ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១៤ ដល់ ១៥ (ភាសាអង់គ្លេស)។

៧. ក្នុងការឆ្លើយតបទៅនឹងបញ្ហាសុខភាពដែលធ្វើឱ្យ ខៀវ សំផន ចេញពីបន្ទប់សវនាការនៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥ អ្នកជំនាញបានសន្និដ្ឋានថា ការពិត ខៀវ សំផន មិនស្រួលខ្លួនតាំងពីមុនពេលកិច្ចដំណើរការនីតិវិធីចាប់ផ្តើមម្ល៉េះ[20]។ បញ្ហានានានៅថ្ងៃទី ២១ និង ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ អាចបណ្តាលមកពីការហត់នឿយផ្នែករាងកាយរបស់គាត់[21]។ ខៀវ សំផន បានប្រាប់អ្នកជំនាញថា គាត់នឹងមានពេលវេលាគ្រប់គ្រាន់ដើម្បីសម្រាក ប្រសិនបើអង្គជំនុំជម្រះបញ្ចប់សវនាការពេលព្រឹកត្រឹមម៉ោង ១១:៣០ ព្រឹក និងចាប់ផ្តើមសវនាការពេលរសៀលពីម៉ោង ១:៣០ រសៀល ដោយទុកឱ្យគាត់មានពេលពីរម៉ោងដើម្បីសម្រាក[22]។ អ្នកជំនាញបានផ្តល់យោបល់ថា ការលើកឡើងនោះជាការសមស្រប[23]។ អ្នកជំនាញបានថ្លែងថា ខៀវ សំផន អាចចូលរួមក្នុងសវនាការបួនថ្ងៃក្នុងមួយសប្តាហ៍បាន[24] ហើយថា រយៈពេលបួនថ្ងៃក្នុងមួយសប្តាហ៍ ដោយមានពេលពីរម៉ោងសម្រាប់សម្រាកទទួលទានអាហារថ្ងៃត្រង់ គួរតែគ្រប់គ្រាន់ដើម្បីកាត់បន្ថយការហត់នឿយរបស់គាត់បាន[25]។

៨. គ្មានភាគីណាមួយ បានជំទាស់ទៅលើរបាយការណ៍របស់អ្នកជំនាញឡើយ។

## ៣. ច្បាប់អនុវត្ត

៩. ដើម្បីកំណត់ថា មានសម្បទាក្នុងការចូលរួមសវនាការ ជនជាប់ចោទត្រូវមានលទ្ធភាពក្នុងការចូលរួមសវនាការប្រកបដោយអត្ថន័យ ដែលមានន័យថា គាត់អាចអនុវត្តសិទ្ធិរបស់គាត់ក្នុងការទទួល

---

[20] សារអេឡិចត្រូនិករបស់អ្នកជំនាញលើកទី២ ទំព័រ ១ ដល់ ២ (ភាសាអង់គ្លេស)។ ប្រតិចារិកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ២៧ (ភាសាអង់គ្លេស)។

[21] សារអេឡិចត្រូនិករបស់អ្នកជំនាញលើកទី២ ទំព័រ ២ (ភាសាអង់គ្លេស)។ ប្រតិចារិកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ២៦ ដល់ ២៨ (ភាសាអង់គ្លេស)។

[22] សារអេឡិចត្រូនិករបស់អ្នកជំនាញលើកទី២ ទំព័រ ២ (ភាសាអង់គ្លេស)។

[23] សារអេឡិចត្រូនិករបស់អ្នកជំនាញលើកទី២ ទំព័រ ២ (ភាសាអង់គ្លេស)។

[24] សារអេឡិចត្រូនិករបស់អ្នកជំនាញលើកទី១ ទំព័រ ២ (ភាសាអង់គ្លេស)។

[25] សារអេឡិចត្រូនិករបស់អ្នកជំនាញលើកទី២ ទំព័រ ២ (ភាសាអង់គ្លេស)។ ប្រតិចារិកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ៣៤ ដល់ ៣៦ (ភាសាអង់គ្លេស)។

បានការជំនុំជម្រះដោយយុត្តិធម៌ និងឆាប់រហ័ស នៅក្នុងកំរិតមួយដែលគាត់អាចចូលរួមដោយមានប្រសិទ្ធភាព ហើយយល់ដឹងពីផ្នែកសំខាន់ៗនៃកិច្ចដំណើការនីតិវិធី[26]។

## ៤. សម្អាងហេតុ

១០. ដើម្បីវាយតម្លៃថាតើ ជនជាប់ចោទមានសម្បទាក្នុងការចូលរួមសវនាការ ឬយ៉ាងណានោះ អង្គជំនុំជម្រះពិចារណាអំពីកត្តាទាំងអស់ដែលពាក់ព័ន្ធ រួមមានភស្តុតាងនានាពីអ្នកជំនាញ ការសង្កេតរបស់អង្គជំនុំជម្រះផ្ទាល់ ផលប៉ះពាល់ទៅលើស្ថានភាពសុខភាពរបស់ជនជាប់ចោទ ភាពរកបាននៃវិធានការអនុវត្តដើម្បីជួយសម្រួលផលប៉ះពាល់នៃការចុះខ្សោយ ហើយថា ជនជាប់ចោទត្រូវបានតំណាង និងផ្តល់ការប្រឹក្សាយោបល់ពីក្រុមមេធាវីដែលមានសមត្ថភាព។

១១. បន្ទាប់ពីបានពិនិត្យមើលទៅលើរបាយការណ៍ស្តីពី ខៀវ សំផន និងភស្តុតាងដែលផ្តល់ដោយអ្នកជំនាញនៅឯសវនាការថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ រួចមក អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ខៀវ សំផន នៅតែមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ហើយនាពេលថ្មីៗនេះគាត់មិនបានទទួលរងនូវការចុះខ្សោយផ្នែកបញ្ញាស្មារតី ឬផ្លូវកាយ ដែលរារាំងមិនឲ្យគាត់ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសម្រាប់សំណុំរឿង ០០២/០២ ឡើយ។ នៅក្នុងសវនាការ មេធាវីអន្តរ-ជាតិការពារក្តី ខៀវ សំផន បានថ្លែងថា ខ្លួនមិនជំទាស់ទៅនឹងសេចក្តីសន្និដ្ឋានថា ខៀវ សំផន នៅមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការទេ[27]។

១២. អនុលោមទៅតាមអនុសាសន៍របស់អ្នកជំនាញ អង្គជំនុំជម្រះបានកែសម្រួលកាលវិភាគសវនាការរបស់ខ្លួន ដើម្បីបញ្ចូលការឈប់សម្រាកពីរម៉ោងសម្រាប់អាហារថ្ងៃត្រង់ ដើម្បីផ្តល់ពេលសម្រាកថ្ងៃត្រង់ឲ្យបានយូរដល់ ខៀវ សំផន។ ដូចដែលបានប្រកាសក្នុងសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះកាលពីថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ រួចមកហើយ គឺថា អង្គជំនុំជម្រះសាលាដំបូងនឹងដំណើរការសវនាការរៀងរាល់ថ្ងៃពីម៉ោង ៩:០០ ព្រឹក រហូតដល់ម៉ោង ១១:៣០ ព្រឹក និងបន្តពីម៉ោង ១:៣០ រសៀល រហូតដល់ម៉ោង ៤:០០ រសៀល ជាទូទៅពីថ្ងៃ ច័ន្ទ ដល់ថ្ងៃ ព្រហស្បតិ៍[28]។

---

[26] រឿងក្តី *Strugar* កថាខណ្ឌ ៥៥។

[27] ប្រតិចារឹកថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ៥៩ (ភាសាអង់គ្លេស)។

[28] ប្រតិចារឹកថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ២៥ ដល់ ២៦ (ភាសាអង់គ្លេស)។

១៣. អង្គជំនុំជម្រះនឹងបន្តចាត់វិធានអនុវត្តផ្សេងៗទៀត ដូចជា ការអនុញ្ញាតឱ្យជនជាប់ចោទចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការ តាមមធ្យោបាយសោតទស្សន៍ពីបន្ទប់ឃុំខ្លួនដែលស្ថិតនៅខាងក្រោមសាលសវនាការ អនុលោមតាមវិធាន ៨១(៥) នៃវិធានផ្ទៃក្នុង ក្នុងករណីចាំបាច់។ អង្គជំនុំ-ជម្រះសន្និដ្ឋានថា វិធានការទាំងនេះនឹងជួយសម្រួលគ្រប់គ្រាន់ដល់ភាពចុះខ្សោយផ្នែកលើស្ថានភាពសុខភាពរបស់ ខៀវ សំផន។ នាពេលអនាគត ក្នុងករណីសមស្រប អង្គជំនុំជម្រះក៏នឹងចេញដីកាសម្រេចអនុវត្តទៅតាមអនុសាសន៍របស់អ្នកជំនាញ ដើម្បីបង្កើនការតាមដានសម្គាល់ឈាមរបស់ ខៀវ សំផន ការពិនិត្យទៅលើមុខងារសតិបញ្ញាស្មារតីរបស់គាត់ និងអនុសាសន៍នានាដើម្បីវាយ-តម្លៃទៅលើលទ្ធភាពរបស់គាត់ក្នុងការអានក្នុងបន្ទប់សវនាការ បន្ទាប់ពីបានកំណត់នូវវិធីសាស្ត្រសមស្របបំផុតក្នុងការធ្វើបែបនេះ។

**តាមសម្អាងហេតុដូចដែលបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូង៖**

**បញ្ជាក់** ថា ជនជាប់ចោទ ខៀវ សំផន នៅតែមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។

ភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE PREMIÈRE INSTANCE

**និល ណុន**